# ស្ថាបត្យកម្មបុរាណមួយស្ថិតក្នុងវត្តទឹកថ្លា

វត្តទឹកថ្លា ស្ថិតក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ តាំងនៅប្រប មហាវិថីសហព័ន្ធរុស្ស៊ី។ ក្នុងបរិវេណវត្តនេះ មានសំណង់បុរាណតូចមួយសង់ឡើងអំពីបេតុង តុបតែងលម្អប្រកបដោយក្បាច់រចនាផ្សេងៗ និងមានអក្សរចារឹកនៅលើផ្នែកខ្លះនៃសំណង់គួរឱ្យចាប់អារម្មណ៍ក្រៃលែង។ ផ្អែកលើអក្សរចារឹកលើជញ្ជាំងផ្នែកខាងជើងដែលរចនាចេញជាលេខសកល១៩២៨(1928?) នាំឱ្យគេយល់ថា សំណង់នេះមានអាយុកាលជិត១០០ឆ្នាំហើយបើគិតមកដល់បច្ចុប្បន្ន។

អ្នកផងទូទៅ តែងហៅសំណង់ដែលមានអាយុកាលជិត១សតវត្សខាងលើនេះថា "វិហារ" ឬបន្ថែមពាក្យថា "វិហារបុរាណ" ឬ "វិហារកាត់ចិន" ផងក៏មាន។ ការហៅនេះទំនងផ្អែកលើលេខ១៩២៨ ក្នុងគំនិតយល់ថាជាឆ្នាំកសាងព្រះវិហារនោះ ដូចបានបញ្ជាក់មកខាងដើម និងអក្សរចារឹកជាភាសាចិនជាច្រើនកន្លែង ដែលគេរចនាក្នុងចន្លោះរង្វង់ធំៗលើជញ្ជាំង។ ប៉ុន្តែមានផ្នែកខ្លះទៀត សិល្បករបានរចនាលម្អដោយតួអក្សរឡាតាំងក្នុងចន្លោះរង្វង់ធំៗនោះដូចអក្សរចិនដែរ។ ទន្ទឹមនឹងនេះ បើតាមការសិក្សារបស់ *Daniel Guéret* និង *Doninique-Pierre Guéret* ក៏យល់ឃើញថាវិហារនេះសង់ឆ្នាំ១៩២៨ និង១៩៣០។[១] លើសពីនេះ បើយោងតាមសំណេរលើជញ្ជាំងផ្នែកខាងលិចបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៩០ វិហារនេះធ្លាប់បានជួសជុល និងលាបពណ៌ម្តងទៀត។

យ៉ាងណាក៏ដោយ ប្រសិនកាត់យល់ដោយស្មាន សំណង់វិហារនេះទំហំប្រហែល ១០ម៉ែត្រ គុណ១៥ ម៉ែត្រប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ បើពិនិត្យលក្ខណៈទូទៅនៃស្ថាបត្យកម្មហាក់មានសណ្ឋានដូចវិហារជហ្វា៤ ដំបូលជ្រាលបីថ្នាក់។[២] នៅផ្នែកខាងចុងមេដំបូលមុខបំពាក់ដោយជហ្វា២ ផ្នែកខាងចុងមេដំបូលក្រោយបំពាក់ដោយជហ្វា២ ហើយតាមចែងនីមួយៗបំពាក់ដោយនាគដងក្តារ។ អ្វីដែលគួរឱ្យកត់សម្គាល់នៃការរចនាដំបូលវិហារខាងលើនេះ គឺដំបូលទាំងមូលជាសាច់បេតុងចាក់គ្រប់ពីលើ ពោលគេពុំប្រើក្បឿងឡើយ ហើយផ្ទៃដំបូលទាំងមូលសោត សិល្បករបានច្នៃដាំលម្អដោយបំណែកអំបែងចាន និង

---

[១] Daniel Guéret & Doninique-Pierre Guéret 2017: 66-67

[២] ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ថាសលោហៈរំលេចពណ៌ចម្រុះ។ ចំណែករងស្បូវ ជាប្រភេទក្បាច់ចាក់ពុម្ពស៊ីម៉ងត៍ក្នុងទម្រង់ជាក្បាច់កញ្ចាំង។[៣] រីឯហោជាងទាំងពីរ (មុខ-ក្រោយ) គេឆ្លាក់ជារូបទេពគង់លើរាជសី ទ្រង់ព្រះខ័នក្នុងព្រះហស្តទាំងសងខាង ហើយព័ទ្ធដោយក្បាច់ភ្ញីទេសបំបែក។

ដោយឡែក វិហារនេះពុំសង់ឡើងនៅលើខឿនថ្នាក់ៗ និងពុំឃើញមានសេសសល់សន្ទឹកសីមាដូចវិហារដទៃឡើយ។ ប៉ុន្តែគេបានសាងឡើងដោយលៃថ្ងៃឱ្យមានកន្លែងដើរប្រទក្សិណកម្ពស់ប្រហែលជាង១ម៉ែត្រ និងបង្កាន់ដៃដែកព័ទ្ធជុំវិញ។ នៅផ្នែកខាងមុខមានទ្វារពីរ ផ្នែកខាងក្រោយមានទ្វារពីរ ហើយលើជញ្ជាំងខាងជើងមានបង្អួចបួន និងលើជញ្ជាំងខាងត្បូងមានបង្អួចបួនដែរ។ រីឯក្បាលសសរ និងក្បាច់លម្អលើចន្លោះរង្វង់តាមជញ្ជាំងនីមួយៗ ហាក់មានលំនាំដូចសិល្បៈប៉ែកអឺរ៉ុប។ ចំពោះក្បាច់លម្អរាងត្រីកោណលើទ្វារ និងបង្អួចនីមួយៗទំនងបំពាក់លម្អក្នុងទសវត្សរ៍ទី៩០ ក្នុងពេលជួសជុលលាបពណ៌ឡើងវិញ។ នៅផ្នែកខាងក្នុង មានសសរបេតុងមូលចំនួន៨ដើម។ នៅលើផ្ទៃជញ្ជាំងត្រឹមលើបង្អួច និងផ្ទៃដំបូលមួយផ្នែកខាងក្នុង លម្អដោយគំនូររឿងពុទ្ធប្រវត្តិ។ តួអង្គក្នុងគំនូរខ្លះ ហាក់មានឥទ្ធិពលផ្នែកសម្លៀកបំពាក់ពីប៉ែកបស្ចិមប្រទេសខ្លះដែរ។

បច្ចុប្បន្នវិហារនេះត្រូវបានបិទទ្វារចោល ពុំបើកជាសារធារណៈឡើយ។ គេសង្កេតឃើញចន្លោះល្វែងខាងក្នុងវិហារ ត្រូវបានរៀបចំតម្កល់អដ្ឋិធាតុ និងគ្រឿងសក្ការៈចាស់ៗជាច្រើន។ ប៉ុន្តែទោះបីយ៉ាងណា បើធៀបនឹងវត្តផ្សេងទៀតក្នុងទីក្រុង វត្តនេះជាវត្តដែលមានសំណង់បុរាណមួយប្រកបដោយទឹកដៃសិល្បៈ និងក្បាច់រចនាតុបតែងលម្អចម្រុះគួរឱ្យចាប់អារម្មណ៍ ជាពិសេសគឺការនិយមយកបំណែកអំបែងចាន (សេរ៉ាមិច, Ceramic) មកបិទរំលេចលើផ្នែកសំខាន់ៗនៃសំណង់ ដូចលំនាំចេតិយបុរាណធំៗលើភ្នំព្រះរាជទ្រព្យ៕

[៣] ច័ន្ទ វិត្ថារិទ្ធ និងព្រាប ចាន់ម៉ារ៉ា ២០០៥: ៣៨៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

AMS KHMER CIVILIZATION

# បញ្ជីរូបភាព



រូបលេខ១ ទិដ្ឋភាពព្រះវិហារមើលពីខាងកើត



រូបលេខ២ រចនាសម្ព័ន្ធដំបូល និងការតុបតែងលម្អ



រូបលេខ៣ ក្បាច់លម្អលើហោជាង



រូបលេខ៤ ទេពគង់លើរាជសីលម្អលើហោជាង







រូបលេខ៥, ៦, និង៧ លេខ និងអក្សរចារឹកផ្សេងៗនៅតាមជញ្ជាំងវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៨ លំនាំក្បាច់លម្អលើទ្វារ និងបង្អួច



រូបលេខ៩ ក្បាច់ក្បាលសសរខាងក្រៅ



រូបលេខ១០ ទិដ្ឋភាពទូទៅក្នុងព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១១ កោដ្ឋ និងគ្រឿងសក្ការៈផ្សេងៗតម្កល់ក្នុងព្រះវិហារ



រូបលេខ១២ កោដ្ឋ និងគ្រឿងសក្ការៈផ្សេងៗតម្កល់ក្នុងព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ច័ន្ទ វិត្ថារិទ្ធ និង ព្រាប ចាន់ម៉ារ៉ា

២០០៩, *ក្បាច់ខ្មែរ*, រៃឃំ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត